# កិច្ចសន្យា

ស្តីពី

ការវិនិយោគដាំដើមម៉ៃសាក់ឡើងវិញ និងសាងសង់រោងចក្រកែច្នៃ

រវាង

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

និង

ក្រុមហ៊ុនGLOBAL AGRICULTURAL DEVELOPMENT (CAMBODIA) Co.; LTD

# AGREEMENT

For

PLANTATION OF TEAK TREE (TECTONA GRANDIS), AND PROCESSING FACTORY

Between

The Ministry of Agriculture, Forestry and Fisheries

And

GLOBAL AGRICULTURAL DEVELOPMENT (CAMBODIA) Co.; LTD

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចសន្យា

## ស្តីពី

## ការវិនិយោគដាំដើមម៉ៃសាក់ឡើងវិញ និងសាងសង់រោងចក្រកែច្នៃ

រវាង

## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

និង

## ក្រុមហ៊ុន GLOBAL AGRICULTURAL DEVELOPMENT (CAMBODIA) Co.; LTD

<u>កិច្ចសន្យានេះធ្វើឡើងរវាង</u> :

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ តំណាងដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានអាស័យដ្ឋានលេខ: ២០០ មហាវិថីព្រះនរោត្តម ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១៧ ៣២០ មានគណនីលេខ : .................................................. នៅធនាគារជាតិនៃ កម្ពុជាហៅថា ភាគី "ក" ។

ជាមួយនិង

ក្រុមហ៊ុន GLOBAL AGRICULTURAL DEVELOPMENT (CAMBODIA) Co.; LTD មានស្នាក់ការនៅ ផ្ទះលេខ ១៥៣៣ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ទូរស័ព្ទលេខ ០១២ ៩៦៧ ៧២២ ដែលតំណាងដោយលោកស្រី KWOK LAI NGAN WAN ជនជាតិ អាមេរិក ឋានៈ នាយកក្រុមហ៊ុន មានគណនីលេខ ០១ ០០ ៣០៦ ០២៨ ០២៨ នៅធនាគារ កាណាឌីយ៉ា អាស័យដ្ឋាន អាគារលេខ ២៦៥-២៦៩ ផ្លូវអង្គដួង រាជធានីភ្នំពេញ ហៅថា ភាគី "ខ" ។

យោង : -ច្បាប់វិនិយោគនៃ ព្រះរាជាណាចក្រកម្ពុជា និង ច្បាប់វិសោធនកម្មនៃច្បាប់វិនិយោគនៃ ព្រះរាជាណាចក្រ កម្ពុជា

-ច្បាប់ភូមិបាលនៃ ព្រះរាជាណាចក្រកម្ពុជា

-តាមខ្លឹមសារលិខិតជូនដំណឹងលេខ ២២៧ សជណ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៦ របស់ ទីស្តីការគណៈរដ្ឋមន្ត្រី

-លិខិតសិទ្ធិប្រទានលេខ ១៥ សប្រទ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ របស់ រាជរដ្ឋាភិបាលកម្ពុជា ។

ភាគីទាំងពីរបានឯកភាពគ្នាលើប្រការទាំងឡាយ មានដូចខាងក្រោមនេះ :

## ប្រការ១ : កម្មវត្ថុនៃកិច្ចសន្យា

កម្មវត្ថុនៃកិច្ចសន្យានេះគឺភាគី "ក" យល់ព្រមផ្តល់ដីសម្បទានដែលមានផ្ទៃក្រឡាសរុបចំនួនប្រាំបួនពាន់ ប្រាំបីរយ (៩.៨០០) ហិកតា ដែលមានទីតាំងស្ថិតនៅក្នុង ស្រុកសំបូរ ខេត្តក្រចេះ ជូនទៅភាគី "ខ" កាន់កាប់ប្រើប្រាស់ធ្វើវិនិយោគ ស្តារព្រៃឈើឡើងវិញដោយ ដាំដើមម៉ៃសាក់ និងបង្កើតរោងចក្រកែច្នៃ ។ ទំហំផ្ទៃដីនេះបានបញ្ជាក់កាន់តែច្បាស់ក្នុងគំនូសផែនទីចង្អុលទីតាំង ដែលបានបញ្ជាក់ពីអាជ្ញាធរខេត្ត និងជំនាញមូលដ្ឋាន ដែលភ្ជាប់មកជាមួយជាឧបសម្ព័ន្ធ នៃ កិច្ចសន្យានេះ ដែលចាប់ពីពេលនេះតទៅហៅថា "ទីតាំង" និងមានកូអ័រដោណេដូចខាងក្រោម :

-ចំនុច (X:៦២០០០០-Y:១៤២១០០០)
-ចំនុច (X:៦២០០០០-Y:១៤៣ ៧០០០)
-ចំនុច (X:៦២៧០០០-Y:១៤៣៧០០០)
-ចំនុច (X:៦២៧០០០-Y:១៤២១០០០) ។

យោងតាមកំណត់ហេតុចុះពិនិត្យសិក្សាវាយតម្លៃសំណើសុំដីសម្បទានចំនួន ប្រាំបួនពាន់ ប្រាំបីរយ (៩.៨០០) ហិកតា របស់ក្រុមហ៊ុន ASIA WORLD AGRICULTURAL DEVELOPMENT (CAMBODIA) Co.; LID ចុះថ្ងៃ ទី ១៣ ខែ មករា ឆ្នាំ ២០០៦ (ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ) ក្នុងចំនួនផ្ទៃដីសរុប ប្រាំបួនពាន់ ប្រាំបីរយ (៩.៨០០) ហិកតា ខាងលើនេះមាន :

១.១ ដីដែលភាគី "ខ" អាចធ្វើអាជីវកម្មដោយផ្ទាល់គឺ ចំណែកដីមិនពាក់ព័ន្ធនឹងដីពលរដ្ឋកាន់កាប់ស្របច្បាប់ និងដីដែលត្រូវរក្សាទុកជាលក្ខណៈធម្មជាតិ ដូចក្នុងចំណុច ១.២ និង ចំណុច ១.៣ នៃប្រការ ១ នេះ ។

១.២ ដីរបស់ពលរដ្ឋកាន់កាប់ដោយស្របច្បាប់ និងដីរបស់ប្រជាពលរដ្ឋកំពុងប្រកបរបរអាជីវកម្មកសិកម្មគ្រួសារ ត្រូវកាត់ចេញ ឬ ក្រុមហ៊ុនអាចសហការធ្វើអាជីវកម្មជាមួយប្រជាពលរដ្ឋដោយមានការយល់ព្រមទាំងសងខាង ។ ក្នុងករណីមានការរំលោភកាន់កាប់ដីសម្បទាននេះដោយខុសច្បាប់ ភាគី "ខ" មានសិទ្ធិប្តឹងតវ៉ាទៅស្ថាប័នមានសមត្ថកិច្ច ។

១.៣ តំបន់បេតិកភណ្ឌវប្បធម៌ជាតិ ដីភ្នំ ដីអាងទឹក ដីព្រៃជាលក្ខណៈប្រពៃណី និង តំបន់ការពារធម្មជាតិផ្សេងៗទៀត ។ល។ ត្រូវរក្សាទុកអោយស្ថិតនៅជាលក្ខណៈធម្មជាតិ ។

១.៤ ចំនួនផ្ទៃដីដែលមានចែងក្នុងចំនុច ១.១ . ១.២ . ១.៣ ភាគី "ក" និង ភាគី "ខ" ត្រូវសហការជាមួយស្ថាប័នមានសមត្ថកិច្ចសិក្សាស្រាវជ្រាវអង្កេតនិង កំណត់ទីតាំងផ្ទៃដីពាក់ពន្ធ័អោយបានចប់សព្វគ្រប់ក្នុងរយៈពេលបី (០៣) ខែ បន្ទាប់ពីកិច្ចសន្យាត្រូវបានចុះហត្ថលេខា ហើយត្រូវកាត់ចេញ ឬ មូយសម្របសម្រួលសងថ្លៃផ្ទៃដីពាក់ព័ន្ធទាំងអស់ ។ ក្រោយពីបានសិក្សាអង្កេតបានច្បាស់លាស់រួចហើយ ចំណែកនៃដីដែលក្រុមហ៊ុនអាចធ្វើអាជីវកម្មដោយផ្ទាល់បាន ដូចចំណុច ១.១ ភាគី "ខ" ត្រូវស្នើសុំចុះបញ្ជីស្របតាមសារាចរណែនាំ លេខ ០៥ សរណន ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជា ។ រាល់ការចំណាយនៃការចុះអង្កេតកំណត់ទីតាំង និងសម្របសម្រួលសងថ្លៃដីពាក់ព័ន្ធជាបន្ទុក របស់ភាគី "ខ" ។

## ប្រការ២ : អំពីថិរៈវេលា

២.១ កិច្ចសន្យានេះមានរយៈពេលចិតសិប (៧០)ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខានៃកិច្ចសន្យានេះតទៅ ។ សិទ្ធិនៃការកាន់កាប់ដីសម្បទាននឹងត្រូវប្រគល់ជូនបន្ទាប់ពីកិច្ចសន្យានេះចូលជាធរមានទៅតាមផ្លូវជាធម្មតា ។ សេចក្តីជូនដំណឹង បញ្ចប់កិច្ចសន្យាត្រូវផ្តល់ដំណឹងជាមុនចំនួនមួយ (០១) ឆ្នាំ ឬ នៅក្នុងឆ្នាំចុងក្រោយនៃកិច្ចសន្យា

២.២ ភាគី "ខ" មានសិទ្ធិសុំជួលបន្តកិច្ចសន្យាបន្ទាប់ពីរយៈពេលចិតសិប (៧០)ឆ្នាំ។ រយៈពេលមួយ (០១)ឆ្នាំ មុនពេលផុតកំណត់កិច្ចសន្យា ភាគី " ខ " អាចសុំធ្វើវិនិយោគបន្តទៅទៀតហើយការបន្តអាចធ្វើឡើងទៅបានក្នុងករណីមានគោលការណ៍អនុញ្ញាត ពីរាជរដ្ឋាភិបាលកម្ពុជាតាមសំណើររបស់ភាគី " ក " ដោយយោលទៅតាមការអនុវត្តន៍កន្លងមករបស់ភាគី " ខ " និងដោយ មានការពិភាក្សា ឯកភាពពីភាគី " ក " អំពីលក្ខខ័ណ្ឌសម្រាប់កិច្ចសន្យាថ្មី ។

## ប្រការ៣ : គោលដៅ និង កម្មវិធីប្រើប្រាស់

គោលដៅ និង កម្មវិធីប្រើប្រាស់ទីតាំងរបស់ភាគី " ខ " គឺការធ្វើផលិតកម្មអាជីវកម្ម ដោយផ្អែកតាមរបាយការណ៍បច្ចេកទេស-សេដ្ឋកិច្ច និងផែនការមេដែលក្រុមហ៊ុនត្រូវធ្វើដូចចំណុច ៧.៣ នៃមាត្រា ៧ ដែលក្នុងនោះមានគោលសំខាន់ៗដូចតទៅ :

៣.១ គោលដៅផលិតកម្ម-អាជីវកម្ម :

៣.១.១ ផលិតកម្មចំបង : ដាំដើមម៉ៃសាក់

៣.១.២ ផលិតកម្មបន្ទាប់បន្សំ : ដំណាំផ្សេងៗទៀត

៣.១.៣ ការសាងសង់ : សាងសង់រោងចក្រកែច្នៃ

៣.២ កម្មវិធីប្រើប្រាស់ទីតាំង : ភាគី "ខ" ត្រូវប្រើប្រាស់ក្នុងរយៈពេលប្រាំ (០៥)ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យានេះអោយអស់ផ្ទៃដីដែលបានរៀបរាប់ក្នុងចំណុច ១.១ នៃប្រការ១ និង ដីដែលពាក់ពន្ធ័នឹងពលរដ្ឋហើយ ភាគី " ខ " បានសម្របសម្រួលដោះដូរ ឬសងទៅពលរដ្ឋដែលកាន់កាប់នោះរួចរាល់ហើយតាមផែនការឆ្នាំដូចខាងក្រោម :

ឆ្នាំទី១ : ១.៨០០ ហិកតា

ឆ្នាំទី២ : ២.០០០ ហិកតា

ឆ្នាំទី៣ : ២.០០០ ហិកតា

ឆ្នាំទី៤ : ២.០០០ ហិកតា

ឆ្នាំទី៥ : ២.០០០ ហិកតា ។

## ប្រការ៤ : ប្រាក់កក់ និង ថ្លៃឈ្នួល

៤.១ ប្រាក់កក់: ភាគី " ខ " ត្រូវបង់ប្រាក់កក់ចំនួនស្មើ ១ USD (មួយដុល្លាសហរដ្ឋអាមេរិក) ក្នុងមួយហិកតា លើផ្ទៃដីសរុបដូចមានក្នុងប្រការ ១ សម្រាប់ធានាការអនុវត្តន៍កិច្ចសន្យានេះ។ ប្រាក់កក់នេះត្រូវបង់យ៉ាងយឺតបំផុតរយៈពេលបី (០៣) ខែ ក្រោយពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យា ។ ប្រាក់កក់នេះត្រូវបង្វិលសងវិញទៅពេលដែលភាគី " ខ " អនុវត្តការដាំដុះចប់តាមគម្រោងក្នុងប្រការ ៣ ចំណុច ៣.២ ។

៤.២ ភាគី " ខ " ត្រូវបង់ថ្លៃឈ្នួលដីប្រចាំឆ្នាំតាមអត្រាថ្លៃឈ្នួលដីសម្បទានតាមការកំណត់របស់រាជរដ្ឋាភិបាលកម្ពុជា ឬស្ថាប័នមានសមត្ថកិច្ច ។ប្រាក់ឈ្នួលត្រូវបង់ជាប្រចាំចូលថវិការដ្ឋតាមរយៈតពពនីរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទឱ្យបានមុនថ្ងៃទី ៣១ ខែ មករា នៃឆ្នាំទីមួយៗ ។

## ប្រការ១ : កម្មវត្ថុនៃកិច្ចសន្យា

កម្មវត្ថុនៃកិច្ចសន្យានេះគឺភាគី "ក" យល់ព្រមផ្តល់ដីសម្បទានដែលមានផ្ទៃក្រឡាសរុបចំនួនប្រាំបួនពាន់ ប្រាំបីរយ (៩.៨០០) ហិកតា ដែលមានទីតាំងស្ថិតនៅក្នុង ស្រុកសំបូរ ខេត្តក្រចេះ ជូនទៅភាគី "ខ" កាន់កាប់ប្រើប្រាស់ធ្វើវិនិយោគ ស្តារព្រៃឈើឡើងវិញដោយ ដាំដើមម៉ៃសាក់ និងបង្កើតរោងចក្រកែច្នៃ ។ ទំហំផ្ទៃដីនេះបានបញ្ជាក់កាន់តែច្បាស់ក្នុងគំនូសផែនទីចង្អុលទីតាំង ដែលបានបញ្ជាក់ពីអាជ្ញាធរខេត្ត និងជំនាញមូលដ្ឋាន ដែលភ្ជាប់មកជាមួយជាឧបសម្ព័ន្ធ នៃ កិច្ចសន្យានេះ ដែលចាប់ពីពេលនេះតទៅហៅថា "ទីតាំង" និងមានកូអរដោណេដូចខាងក្រោម :

-ចំនុច (X:៦២០០០០-Y:១៤២១០០០) -ចំនុច (X:៦២០០០០-Y:១៤៣ ៧០០០)

-ចំនុច (X:៦២៧០០០-Y:១៤៣៧០០០) -ចំនុច (X:៦២៧០០០-Y:១៤២១០០០) ។

យោងតាមកំណត់ហេតុចុះពិនិត្យសិក្សាវាយតម្លៃសំណើសុំដីសម្បទានចំនួន ប្រាំបួនពាន់ ប្រាំបីរយ (៩.៨០០) ហិកតា របស់ក្រុមហ៊ុន ASIA WORLD AGRICULTURAL DEVELOPMENT (CAMBODIA) Co.; LID ចុះថ្ងៃ ទី ១៣ ខែ មករា ឆ្នាំ ២០០៦ (ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ) ក្នុងចំនួនផ្ទៃដីសរុប ប្រាំបួនពាន់ ប្រាំបីរយ (៩.៨០០) ហិកតា ខាងលើនេះមាន :

១.១ ដីដែលភាគី "ខ" អាចធ្វើអាជីវកម្មដោយផ្ទាល់គឺ ចំណែកដីមិនពាក់ព័ន្ធនឹងដីពលរដ្ឋកាន់កាប់ស្របច្បាប់ និងដីដែលត្រូវរក្សាទុកជាលក្ខណៈធម្មជាតិ ដូចក្នុងចំណុច ១.២ និង ចំណុច ១.៣ នៃប្រការ ១ នេះ ។

១.២ ដីរបស់ពលរដ្ឋកាន់កាប់ដោយស្របច្បាប់ និងដីរបស់ប្រជាពលរដ្ឋកំពុងប្រកបរបរអាជីវកម្មកសិកម្មគ្រួសារ ត្រូវកាត់ចេញ ឬ ក្រុមហ៊ុនអាចសហការធ្វើអាជីវកម្មជាមួយប្រជាពលរដ្ឋដោយមានការយល់ព្រមទាំងសងខាង ។ ក្នុងករណីមានការរំលោភកាន់កាប់ដីសម្បទាននេះដោយខុសច្បាប់ ភាគី "ខ" មានសិទ្ធិប្តឹងតវ៉ាទៅស្ថាប័នមានសមត្ថកិច្ច ។

១.៣ តំបន់បេតិកភណ្ឌវប្បធម៌ជាតិ ដីភ្នំ ដីអាងទឹក ដីព្រៃជាលក្ខណៈប្រពៃណី និង តំបន់ការពារធម្មជាតិផ្សេងៗទៀត ។ល។ ត្រូវរក្សាទុកអោយស្ថិតនៅជាលក្ខណៈធម្មជាតិ ។

១.៤ ចំនួនផ្ទៃដីដែលមានចែងក្នុងចំនុច ១.១ . ១.២ . ១.៣ ភាគី "ក" និង ភាគី "ខ" ត្រូវសហការជាមួយស្ថាប័នមានសមត្ថកិច្ចសិក្សាស្រាវជ្រាវអង្កេតនិង កំណត់ទីតាំងផ្ទៃដីពាក់ពន្ធ័អោយបានចប់សព្វគ្រប់ក្នុងរយៈពេលបី (០៣) ខែ បន្ទាប់ពីកិច្ចសន្យាត្រូវបានចុះហត្ថលេខា ហើយត្រូវកាត់ចេញ ឬ មួយសម្របសម្រួលសងថ្លៃផ្ទៃដីពាក់ព័ន្ធទាំងអស់ ។ ក្រោយពីបានសិក្សាអង្កេតបានច្បាស់លាស់រួចហើយ ចំណែកនៃដីដែលក្រុមហ៊ុនអាចធ្វើអាជីវកម្មដោយផ្ទាល់បាន ដូចចំណុច ១.១ ភាគី "ខ" ត្រូវស្នើសុំចុះបញ្ជីស្របតាមសារាចរណែនាំ លេខ ០៥ សរណន ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជា ។ រាល់ការចំណាយនៃការចុះអង្កេតកំណត់ទីតាំង និងសម្របសម្រួលសងថ្លៃដីពាក់ព័ន្ធជាបន្ទុក របស់ភាគី "ខ" ។

## ប្រការ២ : អំពីថិរៈវេលា

២.១ កិច្ចសន្យានេះមានរយៈពេលចិតសិប (៧០)ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខានៃកិច្ចសន្យានេះតទៅ ។ សិទ្ធិនៃការកាន់កាប់ដីសម្បទាននឹងត្រូវប្រគល់ជូនបន្ទាប់ពីកិច្ចសន្យានេះចូលជាធរមានទៅតាមផ្លូវជាផ្លូវការ ។ សេចក្តីជូនដំណឹង បញ្ចប់កិច្ចសន្យាត្រូវផ្តល់ដំណឹងជាមុនចំនួនមួយ (០១) ឆ្នាំ ឬ នៅក្នុងឆ្នាំចុងក្រោយនៃកិច្ចសន្យា ...

២.២ ភាគី ៉ខ៉ មានសិទ្ធិសុំជួលបន្តកិច្ចសន្យាបន្ទាប់ពីរយៈពេលចិតសិប (៧០)ឆ្នាំ។ រយៈពេលមួយ (០១)ឆ្នាំ មុនពេលផុតកំណត់កិច្ចសន្យា ភាគី ៉ ខ ៉ អាចសុំធ្វើវិនិយោគបន្តទៅទៀតហើយការបន្តអាចធ្វើឡើងទៅបានក្នុងករណីមានគោលការណ៍អនុញ្ញាត ពីរាជរដ្ឋាភិបាលកម្ពុជាតាមសំណើររបស់ភាគី ៉ ក ៉ ដោយយោលទៅតាមការអនុវត្តន៍កន្លងមករបស់ភាគី ៉ ខ ៉ និងដោយ មានការពិភាក្សា ឯកភាពពីភាគី ៉ ក ៉ អំពីលក្ខខ័ណ្ឌសម្រាប់កិច្ចសន្យាថ្មី ។

## ប្រការ៣ : គោលដៅ និង កម្មវិធីប្រើប្រាស់

គោលដៅ និង កម្មវិធីប្រើប្រាស់ទីតាំងរបស់ភាគី ៉ ខ ៉ គឺការធ្វើផលិតកម្មអាជីវកម្ម ដោយផ្អែកតាមរបាយការណ៍បច្ចេកទេស-សេដ្ឋកិច្ច និងផែនការមេដែលក្រុមហ៊ុនត្រូវធ្វើដូចចំណុច ៧.៣ នៃមាត្រា ៧ ដែលក្នុងនោះមានគោលសំខាន់ៗដូចតទៅ :

៣.១ គោលដៅផលិតកម្ម-អាជីវកម្ម :

៣.១.១ ផលិតកម្មចំបង : ដាំដើមម៉ៃសាក់

៣.១.២ ផលិតកម្មបន្ទាប់បន្សំ : ដំណាំផ្សេងៗទៀត

៣.១.៣ ការសាងសង់ : សាងសង់រោងចក្រកែច្នៃ

៣.២ កម្មវិធីប្រើប្រាស់ទីតាំង : ភាគី ៉ខ៉ត្រូវប្រើប្រាស់ក្នុងរយៈពេលប្រាំ (០៥)ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យានេះអោយអស់ផ្ទៃដីដែលបានរៀបរាប់ក្នុងចំណុច ១.១ នៃប្រការ១ និង ដីដែលពាក់ពន្ធ័នឹងពលរដ្ឋហើយ ភាគី ៉ ខ ៉ បានសម្របសម្រួលដោះដូរ ឬសងទៅពលរដ្ឋដែលកាន់កាប់នោះរួចរាល់ហើយតាមផែនការឆ្នាំដូចខាងក្រោម :

ឆ្នាំទី១ : ១.៨០០ ហិកតា

ឆ្នាំទី២ : ២.០០០ ហិកតា

ឆ្នាំទី៣ : ២.០០០ ហិកតា

ឆ្នាំទី៤ : ២.០០០ ហិកតា

ឆ្នាំទី៥ : ២.០០០ ហិកតា ។

## ប្រការ៤ : ប្រាក់កក់ និង ថ្លៃឈ្នួល

៤.១ ប្រាក់កក់: ភាគី ៉ ខ ៉ ត្រូវបង់ប្រាក់កក់ចំនួនស្មើ ១ USD ( មួយដុល្លាសហរដ្ឋអាមេរិក) ក្នុងមួយហិកតា លើផ្ទៃដីសរុបដូចមានក្នុងប្រការ ១ សម្រាប់ធានាការអនុវត្តន៍កិច្ចសន្យានេះ ។ ប្រាក់កក់នេះត្រូវបង់យ៉ាងយឺតបំផុតរយៈពេលបី (០៣) ខែ ក្រោយពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យា ។ ប្រាក់កក់នេះត្រូវបង្វិលសងវិញទៅពេលដែលភាគី ៉ ខ ៉ អនុវត្តការដាំដុះចប់តាមគម្រោងក្នុងប្រការ ៣ ចំណុច ៣.២ ។

៤.២ ភាគី ៉ ខ ៉ ត្រូវបង់ថ្លៃឈ្នួលដីប្រចាំឆ្នាំតាមអត្រាថ្លៃឈ្នួលដីសម្បទានតាមការកំណត់របស់រាជរដ្ឋាភិបាលកម្ពុជា ឬស្ថាប័នមានសមត្ថកិច្ច ។ប្រាក់ឈ្នួលត្រូវបង់ជាប្រចាំចូលថវិការដ្ឋតាមរយៈគណនីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឱ្យបានមុនថ្ងៃទី ៣១ ខែ មករា នៃឆ្នាំនីមួយៗ ។

៤.៣ ក្នុងករណីមានការយឺតយ៉ាវក្នុងការបង់ប្រាក់ឈ្នួលតាមការកំណត់ដូចមានចែងក្នុងប្រការ ៤.២ ភាគី " ខ " ត្រូវទទួលពិន័យចំនួន ២ % (ពីរភាគរយ) ក្នុងមួយខែលើទឹកប្រាក់ឈ្នួលប្រចាំឆ្នាំនីមួយៗតាមចំនួនខែដែលយឺតយ៉ាវ ។

៤.៤ ភាគី " ខ " ត្រូវមានកាតព្វកិច្ចបង់ពន្ធផ្សេងៗ ទៀតជូនរដ្ឋតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាដែលនៅជាធរមាន ។

## ប្រការ៥ : ការផ្ទេរ ការជួលបន្ត ឬ ការលក់កិច្ចសន្យា

៥.១ ភាគី " ខ " អាចផ្ទេរទៅអោយឧត្តរាធិការីជនរបស់ខ្លួនបាន ។ ដែលហៅថាឧត្តរាធិការីជនស្របច្បាប់គឺជាបុគ្គលទាំងឡាយណាដែលភាគី " ខ " ប្រគល់ឱ្យស្នងកេរមរតករបស់ខ្លួននៅចំពោះមុខច្បាប់ឬបុគ្គលដែលទទួលស្គាល់ជាញាតិពន្ធ ។ ការប្រកាសជូនដំណឹងស្តីពីការផ្ទេរឬសម្រេចណាមួយទៅឱ្យឧត្តរាធិការីជនត្រូវជូនដំណឹងមកភាគី " ក " យ៉ាង តិច ០៦ ខែ មុនពេលចាប់ផ្តើមអនុវត្ត ។

៥.២ ភាគី " ខ " ក្រោមសិទ្ធិទទួលខុសត្រូវរបស់ខ្លួនចំពោះមុខច្បាប់និងកិច្ចសន្យានេះអាចសហការជាមួយក្រុមហ៊ុនដៃគូរបស់ខ្លួនបានដើម្បីអភិវឌ្ឍន៍ផលិតកម្ម-អាជីវកម្ម ដែលស្ថិតនៅក្នុងក្របខ័ណ្ឌដែលមានចែងក្នុងកិច្ចសន្យានេះ ។

៥.៣ ក្នុងករណី ភាគី " ខ " ជួលបន្ត ឬ ផ្ទេរកិច្ចសន្យានេះ ភាគី " ខ " ត្រូវអនុវត្តតាមច្បាប់វិនិយោគ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់វិនិយោគ នៃ ព្រះរាជាណា ចក្រកម្ពុជា និង មានការយល់ព្រមពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតាមសំណើរបស់ភាគី " ក " ។

៥.៤ ដើម្បីរកទុនពីធនាគារក្នុង និង ក្រៅប្រទេសមកពង្រីកការវិនិយោគទុនបន្ថែម ភាគី " ខ " មានសិទ្ធិយកដំណាំ និងទ្រព្យសម្បត្តិដែលបានចំណាយទុនវិនិយោគកន្លងមក នៅលើដីសម្បទាននោះសំរាប់យកទៅធានាបំណុល ។

## ប្រការ៦ : សិទ្ធិ និង កាតព្វកិច្ចរបស់ភាគី " ក "

ភាគី " ក " មានសិទ្ធិ និង កាតព្វកិច្ចដូចខាងក្រោម:

៦.១ ជួយអន្តរាគមន៍ទៅស្ថាប័នដែលពាក់ព័ន្ធ ដើម្បីដោះស្រាយឧប្បត្តិហេតុណាមួយដែលមានអ្នកប្រព្រឹត្តបទល្មើស រំលោភលើសិទ្ធិរបស់ភាគី " ខ " ក្នុងក្របខ័ណ្ឌនៃការអនុវត្តនូវកិច្ចសន្យា និង ការប្រើប្រាស់ទីតាំង ឬ រឹបអូសយកផ្នែកណាមួយនៃទីតាំង ។

៦.២ ពេលដំណើរការគម្រោងវិនិយោគលើតំបន់ដីសម្បទានរបស់ក្រុមហ៊ុន " ក្នុងករណីមានទំនាស់ដីធ្លីវិនិយោគជាមួយប្រជាពលរដ្ឋ អាជ្ញាធរមានសមត្ថកិច្ច មានសិទ្ធបង្អាកដីសម្បទាននេះ ទុកដើម្បីដោះស្រាយ និង ការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋ ហើយបើមានទំនាស់ដីធ្លីរវាងអង្គភាពយោធា និងប្រជាពលរដ្ឋ គឺត្រូវផ្តល់អាទិភាពដោះស្រាយជូនប្រជាពលរដ្ឋ " ។

៦.៣ តាមដានត្រួតពិនិត្យលើ :

- ការអនុវត្តន៍កិច្ចសន្យា របស់ភាគី " ខ "
- ផលប៉ះពាល់លើបរិស្ថាន
- ការងារបច្ចេកទេស និង កម្មវិធីផលិតកម្ម-អាជីវកម្ម របស់ភាគី " ខ " ។

## ប្រការ៧ : សិទ្ធិ និង ភារកិច្ចរបស់ភាគី ៉ខ៉

ភាគី ៉ខ៉ មានសិទ្ធិ និង ភារកិច្ចដូចខាងក្រោម :

៧.១ យល់ព្រមបង់ប្រាក់កក់និងថ្លៃឈ្នួលត្រឹមត្រូវតាមប្រការ៤នៃកិច្ចសន្យានេះរហូតដល់ពេលចប់អាណត្តិ កិច្ចសន្យា ។

៧.២ យល់ព្រមទទួលបន្ទុកចំណាយលើការអង្កេតសិក្សា និងចំណាយសម្របសម្រួលដោះដូរលើដីពាក់ព័ន្ធ ដូចមានចែងក្នុងប្រការ ១.៤ ។

៧.៣ ត្រូវធ្វើផែនការគ្រប់គ្រងនិងអភិវឌ្ឍន៍ទីតាំងជូន៉ក៉ អោយបានយ៉ាងយឺត ០៦ខែ ក្រោយពីថ្ងៃចុះកិច្ចសន្យា។ ផែនការគ្រប់គ្រងនេះត្រូវមានផែនការមេនៃការអភិវឌ្ឍន៍យុទ្ធសាស្រ្ត កម្មវិធីការប្រើប្រាស់ទីតាំង ការប្រើប្រាស់បច្ចេកទេសផ្សេងៗ និងតុល្យភាពនៃផែនការសេដ្ឋកិច្ចហិរញ្ញវត្ថុក្នុងកិច្ចដំណើរការអភិវឌ្ឍន៍រយៈពេលវែង ( រយៈពេលផ្តើមដំណើរការរហូតការប្រើប្រាស់អស់ដីទីតាំងនិង រយៈពេលបន្ត ) ។

ភាគី ៉ខ៉ អាចចុះដំណើរការងារបាន លុះត្រាតែមានការយល់ព្រម លើឯកសារផែនការគ្រប់គ្រងដោយភាគី ៉ក៉ ជាមុនសិន ។

៧.៤ ត្រូវប្រើប្រាស់កម្លាំងពលកម្មក្នុងស្រុកជាចាំបាច់ ក្នុងករណីគ្មានអ្នកឯកខ្មែរក្នុងស្រុក ក្រុមហ៊ុនអាចរើសអ្នកឯកទេសបរទេសដើម្បីជួយណែនាំឬបង្ហាត់បង្ហាញ អំពីការងារបច្ចេកទេសអាជីវកម្មផលិតកម្មតាម សេចក្តីត្រូវការចាំបាច់របស់ខ្លួន ដោយគោរពតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

៧.៥ យកចិត្តទុកដាក់ចំពោះជីវភាពរស់នៅក៏ដូចជាសុខភាព និងការអប់រំដល់បុគ្គលិក កម្មករ និងគ្រួសាររបស់គេ ដោយកសាងលំនៅដ្ឋាន មន្ទីរពេទ្យ វត្តអារាម សាលារៀន មណ្ឌលកំសាន្តលំហែកាយសម្រាប់ ពួកគេអោយបានសមរម្យ។

៧.៦ អនុវត្តការងារអាជីវកម្មតាមគំរោងផែនការដូចជា : ការកាប់ឆ្ការព្រៃ ការធ្វើផ្លូវ និងការប្រើប្រាស់ដី ដោយត្រូវគោរពតាមល័ក្ខខ័ណ្ឌនិរន្តរភាពធនធានធម្មជាតិរបស់ទីតាំង និង ផលប៉ះពាល់លើបរិស្ថានដែលបណ្តាលមក ពីការធ្វើអាជីវកម្ម-ផលិតកម្ម ។

៧.៧ រៀបចំធ្វើផលិតកម្ម - អាជីវកម្មតាមផែនការ ដូចមានចែងក្នុងរបាយការណ៍បច្ចេកទេសសេដ្ឋកិច្ចរបស់ខ្លួន និង ដូចក្នុងប្រការ ៣ និង ប្រការ ៧ នៃចំនុច៧.៣ នៃកិច្ចសន្យានេះនៅលើផ្ទៃដីអាជីវកម្មជាក់ស្តែង ។

៧.៨ មានសិទ្ធិលក់ដូរប្រមូលទិញ បែងចែកចរាចរផលិតផលគ្រប់ប្រភេទទាំងនៅក្នុង និងក្រៅប្រទេស តាមគោលការណ៍ និង ច្បាប់រដ្ឋជាធរមានក្នុងគោលដៅបម្រើឱ្យការវិនិយោគខាងលើ ។

៧.៩ ចំពោះការនាំចូលទព្វសំភារៈគ្រឿងចក្រ គ្រឿងបន្លាស់ វត្ថុធាតុគីមី ដែលបម្រើឱ្យការធ្វើផលិតកម្ម - អាជីវកម្មពាក់ពន្ធ័ និងការបង់ពន្ធអាករផ្សេងៗ គឺអាស្រ័យដោយច្បាប់ របស់ព្រះរាជាណាចក្រកម្ពុជាកំណត់ ។

៧.១០ ត្រូវអនុញ្ញាតអោយភាគី ៉ក៉ និង ស្ថាប័នពាក់ព័ន្ធតាមដានត្រួតពិនិត្យ វាយតម្លៃសកម្មភាពរបស់ខ្លួនអំពីផលប៉ះពាល់បរិស្ថាន ។ ត្រូវអនុវត្តតាមការណែនាំរបស់ភាគី ៉ក៉ និង ស្ថាប័នពាក់ព័ន្ធក្នុងកិច្ចការពារបរិស្ថាន ។

៧.១១ ត្រូវធ្វើរបាយការណ៍អំពីលទ្ធផល នៃការអនុវត្តការងារវិនិយោគលើដីសម្បទាននេះ ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនភាគី ៉ក៉ ។

## ប្រការ៨ : ការអនុញ្ញាតអោយសាងសង់

៨.១ តាមរយៈនេះភាគី ˝ ខ ˝ ត្រូវបានអនុញ្ញាតឱ្យអនុវត្តរាល់កិច្ចការសំណង់លើទីតាំងដែលស្របតាមច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា និងសមស្របនឹងទិសដៅការងារក្នុងប្រការ ៣ នៃកិច្ចសន្យានេះ ។

៨.២ រាល់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗដូចជា ទំនប់ ប្រឡាយ ដែលឱ្យអាចមានផលប៉ះពាល់ដល់តំបន់ ជុំវិញ ត្រូវមានការអនុញ្ញាតពីភាគី ˝ក˝ ឬស្ថាប័នពាក់ព័ន្ធ ។

## ប្រការ៩ : សិទ្ធិនៃការគ្រប់គ្រង

រាល់អចលនៈទ្រព្យ និង ហេដ្ឋារចនាសម្ព័ន្ធព្រមទាំងសមិទ្ធិផលទាំងអស់ដែលបង្កើតឡើងដោយ ភាគី ˝ ខ ˝ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភាគី ˝ខ˝ រហូតផុតសុពលភាពនៃកិច្ចសន្យា ។

## ប្រការ១០ : ការបញ្ចប់កិច្ចសន្យា

១០.១ ភាគី ˝ ខ ˝ មានសិទ្ធិដកហូតចេញពីគម្រោងការងារទាំងមូល ឬ ផ្នែកណាមួយ ក្នុងល័ក្ខខ័ណ្ឌមិនអាចគ្រប់គ្រងបាន បន្ទាប់ពីបានការឯកភាពពីភាគី ˝ ក ˝ ។ ការដកត្រឡប់ទៅវិញ ឬ ការលក់សំភារៈបរិក្ខារោងចក្រនានានាវាដាក់ម៉ាស៊ីន នាវាផ្ទុកទំនិញ យានយន្តផ្សេងៗ និង ប្រដាប់ប្រដារព្រមទាំងមធ្យោបាយដឹកជញ្ជូនផ្សេងៗទៀត និងគ្រឿងដាក់ភ្ជាប់នៅមួយកន្លែង ត្រូវធ្វើទៅតាមច្បាប់និងបទបញ្ញត្តិជាធរមាន ។

១០.២ ក្នុងករណីដែលភាគី ˝ ខ ˝ ដកខ្លួនដោយខ្លួនឯងនោះភាគី ˝ ខ ˝ ត្រូវទទួលខុសត្រូវតាមច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ។

១០.៣ ក្នុងករណីដែលភាគី ˝ ខ ˝ មិនបានចាប់ផ្តើមអនុវត្តនូវសកម្មភាព ដូចមានចែងក្នុងកិច្ចសន្យា ក្នុងរយៈពេល ០១ ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខានេះ រាជរដ្ឋាភិបាលមានសិទ្ធិបញ្ឈប់កិច្ចសន្យាដោយគ្មានល័ក្ខខ័ណ្ឌ និង គ្មានការសង នូវការខាតបង់ឡើយ ។ការបញ្ឈប់បែបនេះនឹងនាំអោយមានការរឹបអូសប្រាក់កក់របស់ភាគី ˝ ខ ˝ ជាសម្បត្តិរដ្ឋ ។

## ប្រការ១១ : វិវាទ និង ការដោះស្រាយ (អាជ្ញាកណ្តាល )

១១.១ ក្នុងករណីដែលមានវិវាទកើតក្នុងរយៈពេលនៃការអនុវត្តន៍កិច្ចសន្យានេះភាគីទាំងពីរ នឹងសម្របសម្រួល ដោះស្រាយដោយយោលទៅតាមសិទ្ធិ និង ភារកិច្ចរបស់ភាគីនីមួយៗដែលមានចែងក្នុងកិច្ចសន្យានេះ ។

១១.២ ក្នុងករណីដែលភាគីទាំងពីរមិនអាចសម្របសម្រួលឬ ដោះស្រាយវិវាទនេះបានក្នុងរយៈពេលហុកសិប៦០ថ្ងៃ វិវាទនេះត្រូវដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាជួយផ្សះផ្សាសម្រុះសម្រួល ។

១១.៣ ក្នុងករណីដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានៅតែមិនអាចផ្សះផ្សាសម្រុះសម្រួលវិវាទនេះបានក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ក្រោយពីបានទទួលសំណើដូចមានចែងក្នុងចំណុចប្រការ ១១.២ ប្រការនេះគូ ភាគីទាំងពីរត្រូវបញ្ជូនសំណុំឯកសារនៃវិវាទនេះទៅតុលាការ នៃ ព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើការវិនិច្ឆ័យតាមច្បាប់ជាធរមាន ។

## ប្រការ១២ ៖ ការទុកជាមិនបានការតែគខ្លះ

ប្រសិនបើល័ក្ខខ័ណ្ឌណាមួយនៃកិច្ចសន្យានេះត្រូវទុកជាមិនបានការឬគ្មានប្រសិទ្ធភាពផ្នែកដទៃទៀតដែលនៅសល់ ត្រូវមានសុពលភាពដូចដែលមានសរសេរជាលាយល័ក្ខអក្សរចំពោះវិសាលភាពទាំងអស់ដែលច្បាប់បានអនុញ្ញាត ។

## ប្រការ១៣ ៖ ច្បាប់អភិបាល

ការព្រមព្រៀងនៃកិច្ចសន្យានេះ ត្រូវគ្រប់គ្រងដោយច្បាប់ នៃ ព្រះរាជាណាចក្រកម្ពុជា ។

## ប្រការ១៤ ៖ ការព្រមព្រៀងទាំងស្រុង

ឯកសារនេះមានការព្រមព្រៀងទាំងស្រុង ដោយភាគីទាំងពីរ និងជំនួសឱ្យទំនាក់ទំនងនិមិត្តរូបឬការព្រមព្រៀងកន្លងមកទោះជាពាក្យសំដី ឬ ដោយលាយល័ក្ខអក្សរដែលជាប់ទាក់ទិននិងកិច្ចសន្យានេះឡើយ ។ កិច្ចសន្យានេះមិនអាចកែប្រែ ឬផ្លាស់ប្តូរបានទេលើកលែងតែមានសរសេរជា លាយល័ក្ខអក្សរដោយមានចុះហត្ថលេខា និងទទួលស្គាល់ដោយ ភាគី ទាំងពីរ ។

## ប្រការ១៥ ៖ ករណីប្រធានសក្តិ

ក្នុងព្រឹត្តិការណ៍ដែលភាគី ៉ខ៉ មិនអាចបំពេញករណីយកិច្ចរបស់ខ្លួនជាផ្នែកឬទាំងស្រុងបានអនុលោមទៅតាមល័ក្ខខ័ណ្ឌផ្សេងៗនៃកិច្ចសន្យានេះដោយសារតែករណីប្រធានសក្តិ ភាគី ៉ខ៉ ត្រូវប្រកាសប្រាប់ ភាគី ៉ក៉ ដោយសរសេរជាលាយលក្ខ័អក្សរបញ្ជាក់ពីហេតុផលរបស់ខ្លួន ហើយកាតព្វកិច្ចរបស់ភាគី ៉ខ៉ នឹងត្រូវបញ្ឈប់ជាបណ្តោះអាសន្នក្នុងកំឡុង ពេលនៃរយៈពេល ដែលជាប់ពាក់ព័ន្ធនោះ ។

ពាក្យៈ ៉ករណីប្រធានសក្តិ ៉ រួមមានភ្លើងឆេះ ទឹកជំនន់ ខ្យល់ព្យុះ សង្គ្រាម រញ្ជួយផែនដី ការរំជើបរំជួលនៃផ្នែក ស៊ីវិលសកម្មភាពការបះបោរ កុប្បកម្ម ការផ្ទុះផ្សេងៗ ការឆ្លងរាលដាលនៃជំងឺផ្សេងៗ ព្រមទាំងព្រឹត្តិការណ៍ ឬ កាលៈទេសៈផ្សេងៗទៀតដែលហួសពីការគ្រប់គ្រងសមស្របរបស់ភាគីទាំងពីរ ។

## ប្រការ១៦ ៖ សិទ្ធិលើធនធានធម្មជាតិ និង កេរដំណែល

១៦.១ មុនពេលភានដីសម្រាប់អភិវឌ្ឍន៍ភាគី ៉ខ៉ ត្រូវសុំការយល់ព្រមពីភាគី ៉ក៉ ក្នុងការកាប់រំលំឬកែច្នៃ និង ដឹកជញ្ជូនឈើដែលមានលើដីនោះ និង ត្រូវបង់ថ្លៃសួយសារនិងបុព្វលាភជូនភាគី ៉ក៉ ដោយផ្អែកតាមគោលការណ៍ និងច្បាប់ស្តីពីព្រៃឈើជាធរមាន ។

១៦.២ នៅក្នុងការកាប់គាស់ដីសំរាប់ធ្វើ ផលិតកម្ម-អាជីវកម្មប្រសិនបើភាគី ៉ខ៉ រកឃើញវត្ថុបុរាណ ឬ វត្ថុដែលជា

គេរដ៏ណោលផ្សេងៗ របស់ជាតិនៅលើដី ឬ ក្រោមដីត្រូវទុកជាទ្រព្យសម្បត្តិរបស់រដ្ឋ ។

## ប្រការ១៧ : ភាសា

កិច្ចសន្យានេះធ្វើនៅរាជធានីភ្នំពេញ ជាភាសាខ្មែរចំនួន ២០ ច្បាប់ និង ភាសាអង់គ្លេស ២០ ច្បាប់ ហើយច្បាប់នីមួយៗ មានតម្លៃស្មើៗគ្នា ។ ក្នុងករណីខ្វែងមតិគ្នាលើការបកស្រាយកិច្ចសន្យាភាសាខ្មែរត្រូវយកជាមូលដ្ឋាន ។

## ប្រការ១៨ : ការចាប់ផ្តើម និង បញ្ចប់កិច្ចសន្យា

កិច្ចសន្យានេះត្រូវបានចូលជាធរមានចាប់ពីថ្ងៃទី...១៥... ខែ...[illegible]......ឆ្នាំ ២០០៦ ហើយត្រូវផុតកំណត់នៅ
ថ្ងៃទី...១៥... ខែ...[illegible]....ឆ្នាំ ២០៧៦ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...១៥.........ខែ...[illegible]...ឆ្នាំ ២០០៦

| តំណាងភាគី "ខ" | តំណាងភាគី "ក" |
| --- | --- |
| ក្រុមហ៊ុន GLOBAL AGRICULTURAL DEVELOPMENT (CAMBODIA) Co.; LTD | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ |
| | ចាន់ សារុន |

<u>កន្លែងតំកល់ឯកសារ</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងផែនការ
- ក្រសួងយុត្តិធម៌
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់
- ក្រសួងឧស្សាហ៍កម្ម រ៉ែ និង ថាមពល
- ក្រសួងបរិស្ថាន
- សាលាខេត្ត ក្រចេះ
- រដ្ឋបាលព្រៃឈើ
- នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
- នាយកដ្ឋានភូមិសាស្ត្រ និង កែលំអដីកសិកម្ម
- នាយកដ្ឋានកសិ-ឧស្សាហកម្ម
- នាយកដ្ឋាននីតិកម្ម កសិកម្ម
- មន្ទីរកសិកម្មខេត្ត ក្រចេះ
- ភាគី "ក"
- ភាគី "ខ"
- កាលប្បវត្តិ-ឯកសារ